៨ ស្តារ ស្ពតវែរ អិលធីឌី
8 星 服 装 有 限 公 司
8 STAR SPORTSWEAR LTD.

# កិច្ចព្រមព្រៀង
## ស្តីពីការព្យួរការងារ

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងដោយក្រុមហ៊ុន ៨ ស្តារ ស្ពតវែរ អិលធីឌី ដែលមានអាស័យដ្ឋាន ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលត្រូវជាភាគី "ក" ជាមួយប្រតិភូបុគ្គលិកពេញសិទ្ធិរបស់ក្រុមហ៊ុន ដែលតំណាងអោយកម្មករនិយោជិតទាំងអស់របស់ក្រុមហ៊ុន ៨ ស្តារ ស្ពតវែរ អិលធីឌី ដែលត្រូវកំណត់ជាភាគី "ខ"។

ភាកគី "ក" ស្នើព្យួរកិច្ចសន្យាការងារភាគី "ខ" ចំនួន ០៣ ដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលទី១៖** ស្នើរសុំព្យួរចំនួន ៣០ ភាគរយនៃចំនួនកម្មករសរុបចំនួន ២៥ថ្ងៃ ចាប់ពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣

**ដំណាក់កាលទី២៖** ស្នើរសុំព្យួរចំនួន ៣០ ភាគរយនៃចំនួនកម្មករសរុបចំនួន ៣១ថ្ងៃ ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៤។

**ដំណាក់កាលទី៣៖** ស្នើរសុំព្យួរចំនួន ៤០ ភាគរយនៃចំនួនកម្មករសរុបចំនួន ២៩ថ្ងៃ ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ ដល់ ថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០២៤។

**បញ្ជាក់៖** រាល់ដំណាក់កាលនីមួយៗខាងលើ ភាគី "ខ" ទទួលបានប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលចំនួន ៤០ដុល្លា ដោយយោងតាមសេចក្តីណែនាំលេខ ០២០/២៣ ក.ប/ស.ណ.ន.ខ.ល និង ភាគី "ក" ឧបត្ថមចំនួន ៤០ដុល្លាផងដែរ។ ក្នុងករណីភាកគី "ក" មានការបញ្ជាទិញច្រើនឡើងវិញ នោះភាកគី "ក" នឹងបញ្ចប់ការព្យួរបន្តក្នុងដំណាក់កាលទី២ ឬ៣ ហើយភាគី "ក" នឹងធ្វើការប៉ះប៉ូវសងទៅដល់គាតី "ខ" ដែលបានឈប់ក្នុងដំណាក់កាលទី១រួចមកហើយនូវចំនួនទឹកប្រាក់ ៤០ដុល្លាបន្ថែមពីលើនៃទឹកប្រាក់ដែលបានព្យួរ។ ភាកគី "ក" និង ភាគី "ខ" បានព្រមព្រៀង និងឯកភាពទាំងស្រុងរាល់ខ្លឹមសារដែលមានចែងខាងលើទាំងអស់។ ភាគីទាំងពីរ "ក" និង "ខ" ព្រមព្រៀងអនុវត្តតាមលក្ខខណ្ឌដូចបានចែងក្នុងខ្លឹមសារខាងលើ ចាប់ពីថ្ងៃចុះហត្ថលេខា និងផ្តិតស្នាមមេដៃនេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០២៣

ភាគី "ខ" ស្នាមមេដៃប្រតិភូបុគ្គលិកពេញសិទ្ធិ

ភាគី "ក" ហត្ថលេខានាយកក្រុមហ៊ុន

១. ស្រី សន
២. ទេព សោភា
៣. អ៊ុក ចាន់រក្សា
៤. សង សីហា
៥. ព្រើង អឿន
៦. ប៉ាំង ប៊ុនធឿន
៧. ហ៊ិន ធឿន
៨. ញឹម សុគន្ធា
៩. អ៊ិន ចាន់នី
១០. សាន់ សាយ
១១. អោ សេងអួន

8 ស្តារ ស្ពតវែរ
8 STAR SPORTSWEAR LTD.